**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធនធានទឹក និងឧតុនិយម**

លេខ ២១៤ សជណ ធទឧ

## សេចក្តីជូនដំណឹង

## ស្តីពី ស្ថានភាពអាកាសធាតុ និងស្ថានភាពទឹកជំនន់ទន្លេមេគង្គ

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីធ្វើការសង្កេត និងតាមដានលើស្ថានភាពអាកាសធាតុរួចមកឃើញថា ប្រព័ន្ធសម្ពាធទាបដែលបានកើតឡើងកាលពីថ្ងៃទី 08 ខែកញ្ញា ឆ្នាំ 2011 កន្លងទៅនោះ បច្ចុប្បន្នកំពុងបង្កើនឥទ្ធិពលនៅលើអាងទន្លេមេគង្គលើក្នុងប្រទេសឡាវ និងថៃ ។ ជាមួយគ្នានេះប្រទេសកម្ពុជាយើងក៏កំពុងបន្តទទួលឥទ្ធិពលពីជ្រលងសម្ពាធទាបផងដែរ ។ កត្តាទាំងនេះនឹងធ្វើឱ្យមានភ្លៀងធ្លាក់ជាបន្តបន្ទាប់ទាំងក្នុងអាងទន្លេមេគង្គលើ (ក្នុងប្រទេសឡាវ និងប្រទេសថៃ) និងទាំងក្នុងប្រទេសកម្ពុជាពិសេសតំបន់ភ្នំ, តំបន់ខ្ពង់រាបភាគខាងជើង និងតំបន់ខ្ពង់រាបភាគឦសាន ។

ទោះបីជាទឹកទន្លេមេគង្គក្នុងប្រទេសកម្ពុជានៅខេត្តស្ទឹងត្រែង ក្រចេះ និងខេត្តកំពង់ចាម បានស្រកចុះបន្តិចក្តីតែតាមការព្យាករណ៍បានបង្ហាញថា ទឹកទន្លេមេគង្គនឹងចាប់កើនឡើងវិញ ចាប់ពីថ្ងៃទី 15 រហូតដល់ដំណាច់ខែកញ្ញា ឆ្នាំ 2011 ។ ស្ថានភាពនេះក៏នឹងធ្វើឱ្យកំពស់ទឹកនៅទន្លេមេគង្គក្រោម ទន្លេបាសាក់ ទន្លេសាប បឹងទន្លេសាប កើនឡើងហើយហូរចូលទៅតាមព្រែក និងធ្វើឱ្យលិចតំបន់ទំនាបនានា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេទាំងអស់ជ្រាបជាព័ត៌មាន ជាពិសេសបងប្អូនប្រជាកសិករដែលប្រកបរបរកសិកម្មនៅតំបន់ទំនាបតាមដងទន្លេមេគង្គ ទន្លេសាប ទន្លេបាសាក់ និងតំបន់លិចទឹកនានា គួរពន្យាការដាំដុះមួយរយៈ (ចាប់ពីពេលនេះរហូតដល់ចុងខែកញ្ញា ឆ្នាំ 2011 ) ដើម្បីចៀសវាងនូវការខូចខាតផ្សេងៗដោយទឹកជំនន់ ។

ក្រសួងធនធានទឹក និងឧតុនិយម នឹងបន្តធ្វើសេចក្តីជូនដំណឹងអំពីស្ថានភាពទឹកជំនន់នេះជាបន្តបន្ទាប់សម្រាប់ជាព័ត៌មានដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១១

**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥

# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh